00239141

D99/3/33

០០១/១៨-០៧-២០០៧/អវតក/កសចស(អបជ០២)

# អង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ** : 001/18-07-2007- អ.វ.ត.ក/ក. ស.ច.ស( អ.ប.ជ 02)
**ដាក់ជូន** : **អង្គបុរេជំនុំជម្រះ**
**កាលបរិច្ឆេទឯកសារ** : 17 វិច្ឆិកា ២០០៨
**ភាគីដាក់** : មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី
**ភាសាដើម** : បារាំង (បកប្រែជាភាសាខ្មែរនិងអង់គ្លេស)
**ប្រភេទឯកសារ** : សាធារណៈ

## ចម្លើយតបទៅនឹងសារណាមិត្តតុលាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**
កាំង ហ្កិចអៀវ ហៅ ឌុច

**សហមេធាវីការពារ**
មេធាវី កា សាវុធ
មេធាវី François ROUX

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 11 / 2008
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ly

00239142

D99/3/33

០០១/១៨-០៧-២០០៧/អវតក/កសចស(អបជ០២)

## **រំលឹកពីនីតិវិធី**

1.ដោយ  យោងតាមសេចក្តីសំរេចចុះថ្ងៃទី 28 តុលា 2008 អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) បានអញ្ជើញភាគីអោយថ្លែងនូវគ្រប់ការអត្ថាធិប្បាយដែលមានប្រយោជន៍នានាទាក់ទងនឹងសញ្ញាណនៃសហាកម្មឧក្រិដ្ឋកម្មរួម  បន្ទាប់ពីបានអញ្ជើញមិត្តតុលាការឲ្យដាក់សារណាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហាព្រះរាជអាជ្ញាប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ព្រមទាំងបង្គាប់ឲ្យដាក់យ៉ាងយូរបំផុតនៅត្រឹមថ្ងៃទី 17 វិច្ឆិកា ២០០៨ វេលាម៉ោង 16 រសៀល។

2.សា  រណាលើកទី១ត្រូវបានបង្ហាញជូនក្នុងនាម និងជាប្រយោជន៍របស់សហាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

3.មេធាវ ីហត្ថលេខីនៃសារណានេះព្រមព្រៀងគ្នាដាក់ជូនការវាយតំលៃចំពោះអង្គបុរេ-ជំនុំជម្រះនូវការពិនិត្យមើលសញ្ញាណមួយផ្សេងទៀតនៃសហាកម្មឧក្រិដ្ឋកម្មរួម ដោយផ្អែកជាសំខាន់ទៅលើការរំលឹក និងការវិភាគនៃកត្តាយុត្តិសាស្ត្រនានា ដែលអនុញ្ញាតឲ្យមានការពិភាក្សាដ៏ទូលំទូលាយមួយ។

## **ការពិភាក្សា**

4.វាគ្រាន ់តែត្រូវបានរំលឹកឡើងវិញនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហាព្រះរាជអាជ្ញាដែលប្រើប្រាស់នូវទំរង់នៃការទទួលខុសត្រូវសហាកម្មឧក្រឹដ្ឋកម្មរួមនោះត្រូវស្ថិតនៅក្រោមបណ្តុំនៃលក្ខខណ្ឌ៤គឺ:

(1) វាត្រូវតែមានចែងនៅក្នុងអត្ថបទដែលពាក់ព័ន្ធនឹងអ.វ.ត.ក ជាលក្ខណៈមិនច្បាស់លាស់និងតុល្យភាព

(2) វាត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិនៅអំឡុងពេលដែលអង្គហេតុបាកើតឡើង

(3) ច្បាប់ដែលចែងអំពីទំរង់នៃការទទួលខុសត្រូវនេះត្រូវតែមានលក្ខណគ្រប់គ្រាន់សំរាប់ពិរុទ្ធជនបាន

(4) ពិរុទ្ធជនត្រូវតែស្ថិតក្នុងសភាពដែលអាចមើលឃើញជាមុនទម្រង់នៃការ________

5.ដូច្នេះនៅទីនេះ វានឹងត្រូវបានរំលឹកពីៈ

- មាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះ " *គ្រប់ជនសង្ស័យទាំងអស់ដែលបានរៀបផែនការ ញុះញង់ បញ្ជា អោយប្រព្រឹត្ត ដែលនាំទៅដល់ការសមគំនិត ឬដែលបានប្រព្រឹត្ត"* នូវបទឧក្រិដ្ឋនានាដែល ស្ថិតនៅក្រោមយុត្តាធិការនេះ។

- កង្វះខាតការប្រើប្រាស់ពាក្យ "សហកម្មឧក្រិដ្ឋកម្មរួម"៖ ចំពោះទស្សនាទាននៃសហកម្មរួមនេះទៅក្នុងការប្រព្រឹត្តបទឧក្រឹដ្ឋ ឬការប្រព្រឹត្តខុសច្បាប់នានា ទៅក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងផែនការ ឬការរួមគំនិតក្នុងបទឧក្រឹដ្ឋ ត្រូវ បានប្រើប្រាស់យ៉ាងទូលំទូលាយដូចគ្នាដែរ នៅមុនការប្រព្រឹត្ត

នៃបទឧក្រិដ្ឋនានា ដែលនាំទៅដល់ការចោទប្រកាន់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ដូចគ្នាដែរ សញ្ញាណផ្សេងៗទៀតនៃផែនការដែលបានព្រមព្រៀងគ្នា (សូមមើល តុលាការ យោធាអន្តរជាតិ ណឺរឹមប៊ែរ/Nuremberg) ឬ នយោបាយនៃមនោវិជ្ជា អនុត្តរភាព ត្រូវបានអភិវឌ្ឍនៅចាប់តាំងពីសម័យសង្គ្រាមលោកលើកទី២។

ដោយគិតទៅដល់មូលហេតុដើម សញ្ញាណនៃការប្រជែងដែលបានលើកឡើងចំពោះការចាប់ខ្លួន ការបង្ខាំងមនុស្សដោយខុសច្បាប់ និងការជន្លៀសមនុស្ស [ជាក់ស្តែងក្នុងសម័យ នៃសហាគមជ្វីវ] ត្រូវបានបង្កើតឡើងនូវសញ្ញាណនៃ ការចូលរួមនៅក្នុងផែនការមួយដែលបាន ព្រមព្រៀងគ្នា។ (សំនុំរឿងឧក្រិដ្ឋកម្ម ចុះថ្ងៃ 23 មករា 1997: ព្រឹត្តប័ត្រព្រហ្មទណ្ឌលេខ 32, D 1997 . 147. សំគាល់ Pradel)

- ជាក់ស្តែង វាលេចឡើង ឌ ុច បានដឹងពីគោលដៅដែលបានកំណត់នៅមន្ទីរ ឃុំឃាំង ស 21 ហើយគាត់មិនអាចធ្វើមិនដឹងមិនឮចំពោះប្រភពនៃការអនុវត្តនូវការធ្វើទុក្ខបុកម្នេញដ៏ឃោរឃៅ ព្រមទាំងការតាមសម្លាប់រង្គាលជីវិតមនុស្ស។

- ចរិកលក្ខណៈអសីលធម៌យ៉ាងធ្ងន់ធ្ងរ ខុសនឹងច្បាប់ ព្រមទាំងការអនុវត្តឲ្យ

ខាង តែបាននូវនយោបាយនៃការធ្វើទារុណកម្ម និងការសំលាប់មនុស្សជាលក្ខណៈប្រព័ន្ធចំនួន 12000 នាក់ មិនអាចអនុញ្ញាត្តិឲ្យគេចផុតពីការទទួលខុសត្រូវរបស់ជនណាម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវជាន់ខ្ពស់បានឡើយព្រោះ ព ួកគេត្រូវតែដឹងជាមុនពីការទទួលខុសត្រូវជាយ ហេ តុរបស់ខ្លួន។

6.ជាថ្ម ីម្តងទៀត សហព្រះរាជអាជ្ញាបានរំលឹក (ទំព័រ ២៧ នៃសារណាបណ្តឹងឧទ្ធរណ៍) អំពីការចូលរួមយ៉ាង មានប្រសិទ្ធិភាពរបស់ឌុច នៅគ្រប់តំណាក់កាលនៃប្រតិបត្តិការរបស់មន្ទីរ ស២១។

7.មេធាវ ីពាក់ព័ន្ធសូមលើកឡើង ៖

I. ការវិភាគទៅលើយុត្តិសាស្ត្ររបស់តុលាការណ៏រឹមបែរ ដើម្បីបង្ហាញអំពីសញ្ញាណនៃសហាកម្មឧក្រឹដ្ឋកម្មរួម ដែលបានបង្កើតនូវការបែងចែកជា ៣ ប្រភេទ៖

- ករណីដែលនៅក្នុងនោះ អ្នកចូលរួមទាំងអស់បានប្រព្រឹត្តនៅទៅតាមផែនការរួម និងហើយពួកគេចេតនាឧក្រឹដ្ឋដូចគ្នា
- ចំពោះករណីដែលជនត្រូវចោទដឹងដោយខ្លួនឯងផ្ទាល់អំពីអត្ថិភាពនៃសហាកម្មចំពោះ ការធ្វើទុក្ខបុកម្នេញដ៏ឃោរឃៅ ហើយមានចេតនាជំរុញឲ្យប្រព្រឹត្ត

- ចំពោះករណីដែលមានអត្ថិភាពនៃផែនការរួម ដើម្បីបន្តអនុវត្តនូវអំពើប្រព្រឹត្តទៅជាក់លាក់មួយ ប៉ុន្តែនៅពេលកំពុងប្រព្រឹត្តអំពើនោះ អំពើមួយផ្សេងទៀតដែលជាផលវិបាកពីធម្មជាតិអាចមើលឃើញទុកជាមុនត្រូវបានប្រប្រព្រឹត្តឡើង ទោះបីជាវាមិនបាន គ្រោងទុកជាមុននៅក្នុងផែនការរួមក៏ដោយ។

8.ប្រស ិនបើយើងប្រៀបធ្មឹមនិយមន័យទាំងបីនេះទៅនឹងករណីឌុច វាមិនអាចជំទាស់បានទេ ជន ជាប់ពិរុទ្ធ ស្ថិតក្រោមវិសាលភាពនៃការអនុវត្តនិយមន័យទាំងពីរចំនុចរបស់សហកម្មឧក្រិដ្ឋកម្មរួម។

II. យុត្តិសាស្ត្រថ្មីៗទាក់ទងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលព្យាយាមឲ្យនិយមន័យនៃសញ្ញាណជាជំនួយ និងការលើកទឹកចិត្តទៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមបានពិចារណា ៖

9.ភស ុតាងនៃអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមតម្រូវដូចតទៅ៖

- ធាតុសំភារៈដែលបង្ហាញពីពហុភាពនៃបុគ្គល អត្ថិភាពនៃផែនការ គំរោងឬចេតនារួម ដែលបង្កើត ឬរួមបញ្ចូលទៅក្នុងការប្រព្រឹត្តនៃបទឧក្រិដ្ឋដែលបានចែងនៅក្នុងលក្ខន្តិកៈ និងការចូលរួមរបស់ជនត្រូវចោទនៅក្នុងគំរោងការរួម

- ធាតុចិត្តសាស្ត្រដែលទាមទារនូវចេតនាចូលរួម ឬជំរុញ អំពើឬកម្មវត្ថុនៃ

ឧក្រិដ្ឋកម្មរួម

ក្នុងពេលដែលបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅលើអំពើដែលត្រូវប្រ ប្រព្រឹត្តក្រៅផែនការរួមត្រូវបានលើកឡើង តែក្នុងករណីការប្រព្រឹត្តនៃ បទឧក្រិដ្ឋធ្វើឡើងដែលអាចគ្រោងទុកជាមុនដោយសមាជិកនៃក្រុម ហើយជនជាប់ចោទមានឆន្ទៈទទួលយកហានិភ័យនោះតែប៉ុណ្ណោះ។

(សាលាឧទ្ធរណ៍ រដ្ឋអាជ្ញា និង Dusko Tadic IT-94-1 សាលាឧទ្ធរណ៍ដីការ ចុះថ្ងៃទី 15 កក្កដា 1999)

III. ម្យ៉ាងទៀត យើងដឹងថានៅក្នុងរឿងក្តី រដ្ឋអាជ្ញា និង Radoslav Brdjanin និង Momir Tali ( សំណុំរឿងលេខ IT-99-36-PT 26 មិថុនា 2000 សាលាដំបូង II)

10. វាត្រូវបានពិចារណាថា " វាត្រូវតែកំណត់ឲ្យបានច្បាស់នូវ អត្តសញ្ញាណ នៃកម្មវត្ថុ នៃសហាកម្មរួម ...ក្នុងករណីដែលសហាកម្មឧក្រិដ្ឋកម្មរួមអាចចោទប្រកាន់នូវកម្មវត្ថុ ឧក្រិដ្ឋកម្មខុសគ្នាជាច្រើនទៀតនោះ វាមិនចាំបាច់ទេដែលការចោទប្រកាន់ត្រូវ បង្ហាញថា អ្នកចូលរួមម្នាក់ៗបានយល់ព្រមចំពោះបទឧក្រិដ្ឋនីមួយៗដែលត្រូវបាន ប្រព្រឹត្តនោះទេ ។

ផ្ទុយមកវិញ វាចាំបាច់សំរាប់ការចោទប្រកាន់ ដែលត្រូវបង្ហាញថាបុគ្គលណា ប្រព្រឹត្តដោយផ្ទាល់ខ្លួនឯងនូវបទឧក្រិដ្ឋដែលជាផលនៃការចោទប្រកាន់ និង ជនដទៃដែលត្រូវបានចោទចូលរួមបទឧក្រិដ្ឋខាងដើមនេះ ដោយសារយ៉ាងហោច

ណាស់វាមានអត្ថិភាពនៃការព្រមព្រៀង (ឬគោលបំណងរួម) ដើម្បីប្រព្រឹត្តនូវបទឧក្រិដ្ឋមួយច្បាស់លាស់។ ដូច្នេះ យើងអាចកំណត់ថាប្រសិនបើឧក្រិដ្ឋកម្មដែលនាំដល់ការចោទប្រកាន់ គឺជាផលវិបាកពីធម្មជាតិ ព្រមទាំងអាចគ្រោងទុកបាននៃបទឧក្រិដ្ឋដំបូង...បើគ្មានភស្តុតាងបញ្ជាក់ចំនុចនេះទេ គ្មានជនណាម្នាក់ត្រូវសន្មត់ថាជាជនត្រូវចោទដែលបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាក្រុមជាមួយចារីនៃឧក្រិដ្ឋកម្មដែលជាផលវិបាកនោះទេ..."។

11. នៅក្នុងករណី ឌុច សហព្រះរាជអាជ្ញាបានបង្ហាញយ៉ាងច្បាស់លាស់ថា ទស្សនៈដូចគ្នានៃអនុវត្តការ សំលាប់រង្គាលគឺមានលក្ខណៈរួមរវាងអ្នកទទួលខុសត្រូវ និងគ្រប់អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្ម នេះ។

12. សារណានៃការចោទប្រកាន់បានបញ្ជាក់អំពីទំរង់ដែលបង្ហាញពីសហកម្មឧក្រិដ្ឋកម្មរួម។

13. សហព្រះរាជអាជ្ញាបានបង្ហាញថា ជនល្មើសមានចេតនាប្រព្រឹត្តអំពើល្មើសឲ្យខាងតែបាន ហើយថា ចេតនានេះត្រូវបានបែងចែកទៅគ្រប់បុគ្គលផ្សេងទៀតដែលរួមបញ្ចូលទៅក្នុងបទឧក្រិដ្ឋនេះ ។

14. នៅគ្រប់សម្មតិកម្មទាំងអស់ ៖

ដែលជាធាតុផ្សំចិត្តសាស្ត្រតម្រូវដូចតទៅ៖យ៉ាងហោចណាស់ចេតនាអាចទាញចេញពីក្នុងបំណង និងសកម្មភាពនៃភ្នាក់ងារ ឬក៏កាលៈទេសៈជុំវិញការប្រព្រឹត្តនៃ

បទល្មើស។

ជនជាប់ចោទត្រូវបានផ្តល់ដំណឹងយ៉ាងពេញលេញនូវការធ្វើទុក្ខបុកម្នេញដ៏ឃោរឃៅ ឃៅជាលក្ខណៈប្រព័ន្ធ ព្រមទាំងត្រូវបានរៀបចំនូវចេតនាសំដៅព្រឹត្តអំពើជាមួយ ទាំងនោះ ដោយប្រើជាក់លាក់នូវឋានៈដ៏មានអំណាចរបស់ខ្លួន ព្រមទាំងដាក់ឲ្យ អនុវត្តពេញលេញនូវផែនការនៃបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់។

ដោយផ្អែកទៅតាមរយៈយុត្តិសាស្ត្រអន្តរជាតិ បទឧក្រិដ្ឋនេះផ្ទុកនូវសញ្ញាណធាតុ ផ្សំ ចេតនាទុច្ចរិតសាយភាយ(dol élargi) ៖ឧុច មានចេតនាពិតប្រាកដនៃការចូលរួម ក្នុងគំរោងការឧក្រិដ្ឋកម្មរួម គឺថាគាត់បានដឹង ដែលយល់បានថាការប្រព្រឹត្តនៃបទ ឧក្រិដ្ឋនានា គឺជាផលវិបាកជាយថាហេតុនៃការអនុវត្តសហកម្មឧក្រិដ្ឋកម្មនេះ ហើយគាត់ព្រមទាំង បានសំរេចក្នុងការចូលរួមក្នុងអំពើរួមនេះជាមួយការយល់ដឹង យ៉ាងច្បាស់លាស់ពីមូលហេតុ។

IV. នៅក្នុងដីកាTadic ដូចមានចែងខាងដើម សាលាឧទ្ធរណ៍បានបង្ហាញពីធាតុចាំ បាច់បីយ៉ាង ដើម្បីបង្កើតពីពិរុទ្ធភាពនៅក្នុងជំរំប្រមូលផ្តុំដូចជា៖

- អត្ថិភាពនៃប្រព័ន្ធដែលបានរៀបចំដើម្បីធ្វើទុក្ខទោសលើអ្នកទោស ព្រម ទាំងប្រព្រឹត្តឧក្រិដ្ឋកម្មដែល បានចោទប្រកាន់
- ការយល់ដឹងរបស់ជនជាប់ចោទពីលក្ខណៈធម្មជាតិនៃប្រព័ន្ធនោះ
- ការចូលរួមយ៉ាងសកម្មក្នុងការបង្កើតប្រព័ន្ធ តាមរយៈជំនួយ ការលើកទឹក

00239150



ចិត្ត ឬក៏ការចូលរួម អនុវត្តនូវគំរោងការឧក្រិដ្ឋកម្មរួម

15. យុត្តិសាស្ត្រនេះបានលើកឡើងជាគោលការណ៍ថា៖ការយល់ដឹងពីអត្ថិភាពនៃសហាកម្មឧក្រិដ្ឋកម្មរួម និងការចូលរួមជាសារជាតិវន្តក្នុងការអនុវត្តផែនការរួមនោះវាគ្រប់គ្រាន់ដើម្បីដាក់ទោសជនណាដែលជួយ ឬក៏លើកទឹកចិត្តដល់ការប្រព្រឹត្តសហាកម្មឧក្រិដ្ឋកម្មរួម។

16. យើងដឹងថា កំរិតនៃការចូលរួមគឺអាចផ្លាស់ប្តូរទៅតាមធម្មជាតិ (តួនាទីដោយផ្ទាល់និងមានសារៈ សំខាន់?)

17. ជនណាដែលជួយ ឬលើកទឹកចិត្តត្រូវទទួលរងនូវការរូបភាពសមគំនិតក្នុងសហាឧក្រិដ្ឋកម្មរួម ជា មួយនឹងសហចារី ទោះបីមិនបានប្រព្រឹត្តដោយផ្ទាល់នៃបទឧក្រិដ្ឋក៏ដោយ។

ប្រសិនបើការចូលរួមរបស់គាត់គឺមានរយៈពេលវែង ឬប្រសិនបើវារួមបញ្ចូលដោយផ្ទាល់ទៅក្នុងដំ ណើរការប្រព្រឹត្តទៅនៃសហាកម្មឧក្រិដ្ឋកម្មរួម។

18. ជាក់ស្តែងមែនហើយថាសញ្ញាណនេះជាសញ្ញាណមួយដែលពិបាកនឹងធ្វើការវាយតម្លៃ ៖ដោយវាតម្រូវទាល់តែការចូលរួម ទោះក្នុងរបៀបណាក៏ដោយ ត្រូវតែបំរើឲ្យផែនការរួម ឬគោលបំណងរួម ។

19. កត្តាជម្រុញទាំងនោះមានដូចខាងជា ៖

- វិសាលភាពនៃការប្រពឹត្តឧក្រិដ្ឋកម្ម

- មុខងារដែលបានបំពេញ
- ឋានៈរបស់ជនជាប់ចោទ
- រយៈពេលនៃការចូលរួមបន្ទាប់ពីបានដឹងពីលក្ខណៈសម្បត្តិនៃការប្រព្រឹត្តសហឧក្រិដ្ឋកម្ម
- ការខិតខំប្រឹងប្រែងផ្សេងៗដើម្បីទប់ស្កាត់សកម្មភាពឧក្រិដ្ឋកម្ម ឬរារាំងការប្រព្រឹត្តទៅដ៏ឥត ខ្ចោះរបស់ប្រព័ន្ធនេះ
- ស្ថានទំងន់ និងវិសាលភាពនៃការប្រព្រឹត្តបទឧក្រិដ្ឋ
- ប្រសិទ្ធិភាព ភាពវៀងវៃ ឬភាពឃោរឃៅ ដាក់ក្នុងការអនុវត្តនៃមុខនាទី
- ភាពសំខាន់នៃការចូលរួម ដែលបន្ត ឬច្រំដែលៗ
- យថាភាពនៃការប្រកាសដោយផ្ទាល់មាត់
- ការប្រព្រឹត្តនៃបទឧក្រិដ្ឋ

(អត្ថបទស្រង់ពី បច្ចុប្បន្នភាព និងនីតិអន្តរជាតិ - ទស្សនាវដ្តី ការវិភាគគតិយុត្តិនៃបច្ចុប្បន្នភាព អន្តរជាតិ។ អត្ថបទរបស់ Céline RENAUT បេក្ខបណ្ឌិតនៅសាកលវិទ្យាល័យ Paris Sud XI)។

20. នៅក្នុងករណី ឌុច ទំហំនៃសហកម្មឧក្រិដ្ឋកម្មរួម គឺអាចកត់សំគាល់បាន ពីតួនាទីដែលបានបំពេញ គឺជាការទទួលខុសត្រូវខ្ពស់បំផុត ។ តាមឋានានុក្រម គឺជាឋានៈខ្ពស់បំផុតមួយ។ ការចូលរួមដោយឋិតថេរនៅក្នុងរយៈពេល ប្រសិទ្ធិភាព និងភាព

យោរយៅនៃវិធីសាស្ត្រនៃការសម្លាប់រង្គាល គឺមិនអាចបង្ហាញត្រឹមតែជាការស្មោក
ស្តាយ
ហើយម្យ៉ាងយើងដឹងថាគ្មានការខិតខំប្រឹងប្រែងណាមួយទាល់តែសោះត្រូវបានអនុវត្ត ដើម្បីប៉ុនប៉ងបញ្ឈប់នូវគំរោងការនោះទេ។

21. ការទទួលខុសត្រូវ ត្រូវតែបានវាយតំលៃជា*លក្ខណៈជាក់ស្តែង*តាមមុខនាទីនេះ

- ការយល់ដឹងពីមូលហេតុនៃដំណើរប្រព្រឹត្តទៅ,
- ឋានៈតាមឋានានុក្រមនៅក្នុងការរៀបចំនៃសហាកម្មឧក្រិដ្ឋកម្មរួម,
- កំរិតនៃការចូលរួម,
- សញ្ញាណនៃការដាក់ឲ្យអនុវត្តការ
  វាផ្សេងពីការគោរពបទបញ្ជាដ៏សាមញ្ញមួយ

V. ជាលក្ខណៈបន្ទាប់បន្សំ ហើយទោះបីជាចង់ពិចារណាថា សហាកម្មឧក្រិដ្ឋកម្មរួម អាច កាត់បន្ថយ –ទៅតាមកំរិតនៃទស្សនទាន - « *ពីមួយក្នុងចំណោមរបៀបនៃការប្រព្រឹត្តបទល្មើសមួយពីក្នុងចំណោមបទល្មើសជាច្រើន ដែលត្រូវបានហាមឃាត់ដោយមាត្រា២ រហូត ដល់ ៥ នៃលក្ខន្តិកៈ"*

ហើយថា ឌុច មិនបានចូលរួមដោយផ្ទាល់ទៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ។ វាមិនបានរិតត្បិតថាយ៉ាងហោចណាស់របៀបនៃការទទួលខុសត្រូវណាមួយអាចត្រូវបានបង្ហាញនោះទេ ដែលតាមរយៈនោះជនជាប់ចោទអាចទទួលខុសត្រូវ

00239153



ជាលក្ខណៈបុគ្គលដោយមិនចាំបាច់ក្លាយចារីដែដល់នៃ បទឧក្រិដ្ឋនោះទេ ផ្ទុយមកវិញរបៀបនេះវាបែរជាសមស្របទៅនឹងលក្ខខណ្ឌដែលកំណត់ដោយ សហាកម្មឧក្រិដ្ឋកម្មរួម ប្រភេទទី ៣ទៅវិញ(ផលវិបាកពីធម្មជាតិ និងការមើល ឃើញទុកជាមុនដោយសមហេតុសមផល) ។

22. នៅទីនោះជាថ្មីម្តងទៀត អាចមើលឃើញថា ឌុចប្រាកដទទួលខុសត្រូវចំពោះការ ចូលរួមរបស់គាត់។

**ដូច្នេះ**

ដើម្បីជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងក្របខណ្ឌនៃសារណាមិត្ត គុលាការមេធាវីដែលមានឈ្មោះខាងក្រោមសន្និដានទទូចឲ្យមានការអនុវត្តនៃ សហាកម្ម ឧក្រិដ្ឋកម្មរួម ( សហាកម្មឧក្រិដ្ឋកម្មរួម ប្រភេទ៣ / ECCIII) នៅចំពោះមុខ អ.វ.ត.ក ក្នុងក្របខណ្ឌនៃការណែនាំពីសារណាឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងទៅនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត។

បំពេញដោយ

មេធាវី Martine JACQUIN

មេធាវី Phillippe CANNONE

ចម្លើយតបទៅនឹងសារណាមិត្តគុលាការ